ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមរដ្ឋប្បវេណី**

-លេខ: ៨៤ "គ១"

ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០២៣

-សំណុំរឿងរដ្ឋប្បវេណីលេខ ១០៦០

ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០២១

# តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានធ្វើការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០២៣ វេលាម៉ោង ០៩ និង ០០ នាទីព្រឹក លើសំណុំរឿងរដ្ឋប្បវេណីលេខ ១០៦០ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០២១ ដោយមានសមាសភាព៖

**ចៅក្រមជំនុំជម្រះ**

-លោកស្រី [redacted] ជាចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ។

**ក្រឡាបញ្ជី**

-លោក [redacted] ជាក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ។

ដើមចោទឈ្មោះ [redacted] សំបូរ ភេទប្រុស កើតថ្ងៃទី ១១ ខែ តុលា ឆ្នាំ១៩៧៩ សញ្ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃផ្ទះ [redacted]។

អ្នកតំណាងដោយអាណត្តិ៖ [redacted]។

ចុងចម្លើយឈ្មោះ [redacted] ធីតា ភេទស្រី ០៩ ខែ កញ្ញា ឆ្នាំ១៩៧៩ សញ្ជាតិខ្មែរ មានទីលំនៅ [redacted]

អ្នកតំណាងដោយអាណត្តិ៖ មេធាវី [redacted]

## I. អង្គហេតុ និងចំណុចវិវាទ

**១-ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ៖**

១-១-សុំលែងលះពីចុងចម្លើយឈ្មោះ [redacted] ធីតា ភេទស្រី កើតថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ១៩៧៩ សញ្ជាតិខ្មែរ។

១-២-សុំប្រគល់កូន ០២នាក់ មានឈ្មោះ [redacted] មុន្នីនាថ ភេទស្រី កើតថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ២០០៣ និងឈ្មោះ [redacted] កល្យាណី ភេទស្រី កើតថ្ងៃទី ៣០ ខែ តុលា ឆ្នាំ២០០៦ ឱ្យទៅចុងចម្លើយ ជាអ្នកគ្រប់គ្រង និងមានសិទ្ធិអំណាចមេបា។

១-៣-ទ្រព្យសម្បត្តិរួមមាន ផ្ទះចំនួន ០១កន្លែង ស្ថិតនៅផ្ទះលេខ ២D ផ្លូវលេខ ២៧១ ភូមិ១១ ក្រុម៣០ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ប្រគល់ឱ្យទៅកូនស្រីទាំងពីរ។

**២-ការពន្យល់ត្រួសៗអំពីរឿងក្តី៖**

នៅក្នុងរឿងនេះ ដើមចោទឈ្មោះ [redacted] សំបូរ និងចុងចម្លើយឈ្មោះ [redacted] ធីតា ពិតជាប្តីប្រពន្ធនឹងគ្នាត្រឹមត្រូវតាមច្បាប់ ដោយមានសំបុត្រអាពាហ៍ពិពាហ៍លេខ ២១២/២០០២ ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ២០០២ ចេញដោយអភិបាលខណ្ឌទួលគោក។ អំឡុងពេលរស់នៅជាប្តីប្រពន្ធ ដើមចោទ និងចុងចម្លើយបង្កើតបានកូន ០២នាក់ មានឈ្មោះ [redacted] មុន្នីនាថ ភេទស្រី កើតថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ២០០៣ និងឈ្មោះ [redacted] កល្យាណី កើតថ្ងៃទី ៣០ ខែ តុលា ឆ្នាំ២០០៦។ ក្រោយពេលរៀបអាពាហ៍ពិពាហ៍រួចមក ដើមចោទ និងចុងចម្លើយរស់នៅមិនចុះសម្រុងរវាងគ្នា ទើបធ្វើឱ្យដើមចោទអស់មនោសញ្ចេតនារួមរស់ជាមួយគ្នាជាប្តីប្រពន្ធតទៅទៀត ហេតុនេះទើបដើមចោទសម្រេចចិត្តដាក់ពាក្យបណ្តឹងមកតុលាការតែម្តង។



Scanned with CamScanner

៣-អង្គហេតុដែលអះអាងដោយដើមចោទ៖

-ឈ្មោះ [redacted]សំបូរ បានអះអាងថា ខ្លួនបានរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ [redacted]ទីតា ដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ តាមសំបុត្រអាពាហ៍ពិពាហ៍លេខ ២១២/២០០២ ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ២០០២ ចេញដោយរដ្ឋបាលខណ្ឌទួលគោក។ អំឡុងពេលរស់នៅជាប្តីប្រពន្ធ ខ្លួននិងចុងចម្លើយបង្កើតបានកូន ០២នាក់ មានឈ្មោះ [redacted]មុន្នីនាថ ភេទស្រី កើតថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ២០០៣ និងឈ្មោះ [redacted]កន្យាណី កើតថ្ងៃទី ៣០ ខែ តុលា ឆ្នាំ២០០៦។ ក្រោយពេលរៀបអាពាហ៍ពិពាហ៍រួចមក ខ្លួននិងចុងចម្លើយរស់នៅមិនចុះសម្រុងរវាងគ្នា ទើបធ្វើឱ្យខ្លួនអស់មនោសញ្ចេតនារួមរស់ជាមួយគ្នាជាប្តីប្រពន្ធតទៅទៀត ហេតុនេះទើបខ្លួនសម្រេចចិត្តដាក់ពាក្យបណ្តឹងមកតុលាការតែម្តង។

ខ្លួនសុំលែងលះពីចុងចម្លើយ , សុំប្រគល់សិទ្ធិគ្រប់គ្រងកូនចំនួន ០២នាក់ មានឈ្មោះ [redacted]មុន្នីនាថ ភេទស្រី កើតថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ២០០៣ និងឈ្មោះ [redacted]កន្យាណី កើតថ្ងៃទី ៣០ ខែ តុលា ឆ្នាំ២០០៦ ទៅឱ្យចុងចម្លើយ និងឯកភាពបង់អាហារកាតព្វកិច្ចសម្រាប់ចិញ្ចឹមកូនឈ្មោះ [redacted]កន្យាណី ក្នុងមួយខែ ចំនួន ២០០$ ហើយកូនឈ្មោះ [redacted]មុន្នីនាថ បង់តាមលទ្ធភាពជាក់ស្តែង។

ចំណែកឯទ្រព្យសម្បត្តិរួមមានផ្ទះចំនួន ០១កន្លែង ស្ថិតនៅផ្ទះលេខ ២D ផ្លូវលេខ ២៧១ ភូមិ១១ ក្រុម៣០ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ខ្លួនឯកភាពប្រគល់ឱ្យទៅកូនស្រីទាំងពីរ។

៤-អង្គហេតុដែលអះអាងដោយចុងចម្លើយ៖

-ឈ្មោះ [redacted]ទីតា បានអះអាងថា ខ្លួនឯកភាពលែងលះពីដើមចោទ។ ចំពោះកូនចំនួន០២នាក់ មានឈ្មោះ [redacted] មុន្នីនាថ ភេទស្រី កើតថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ២០០៣ និងឈ្មោះ [redacted]កន្យាណី កើតថ្ងៃទី ៣០ ខែ តុលា ឆ្នាំ២០០៦ ខ្លួនឯកភាពទទួលសិទ្ធិជាអ្នកមានសិទ្ធិអំណាចមេបា និងឱ្យដើមចោទបង់អាហារកាតព្វកិច្ចសម្រាប់ចិញ្ចឹមកូនឈ្មោះ [redacted] កន្យាណី ក្នុងមួយខែ ចំនួន ២០០$ ហើយកូនឈ្មោះ [redacted]មុន្នីនាថ ឱ្យដើមចោទបង់តាមលទ្ធភាពជាក់ស្តែង។

ចំណែកឯទ្រព្យសម្បត្តិរួមមានផ្ទះចំនួន ០១កន្លែង ស្ថិតនៅផ្ទះលេខ ២D ផ្លូវលេខ ២៧១ ភូមិ១១ ក្រុម៣០ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ខ្លួនឯកភាពប្រគល់ឱ្យទៅកូនស្រីទាំងពីរ។

៥-ចំណុចគ្មានវិវាទ៖

-គូភាគីព្រមព្រៀងគ្នាលែងលះ កំណត់អ្នកមានសិទ្ធិអំណាចមេបាលើកូនទាំងពីរនាក់ ការបង់អាហារកាតព្វកិច្ចសម្រាប់ចិញ្ចឹមកូន និងឯកភាពប្រគល់ទ្រព្យសម្បត្តិរួមទៅឱ្យកូនទាំងពីរនាក់។

៦-ចំណុចវិវាទ៖ គ្មាន។

## II.ការពិនិត្យភស្តុតាង

១-ភស្តុតាងជាឯកសាររបស់ដើមចោទ៖

-សំបុត្រអាពាហ៍ពិពាហ៍លេខ ២១២/២០០២ ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ២០០៥ ចំនួន ០១ច្បាប់។ (ថតចម្លង)

-សំបុត្រកំណើតលេខ ១១៥ ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ២០០៥ ចំនួន ០១ច្បាប់។ (ថតចម្លង)

-សំបុត្រកំណើតលេខ ១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ២០០៧ ចំនួន ០១ច្បាប់។ (ថតចម្លង)

-វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១២០៤០៦១១-០៣៧៨ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ២០០៩ ចំនួន ០១ច្បាប់។ (ថតចម្លង)

២-ភស្តុតាងជាឯកសាររបស់ចុងចម្លើយ៖ គ្មាន។

ក្រៅពីភស្តុតាងដែលភាគីបានដាក់ខាងលើ តុលាការពុំទទួលបានឯកសារផ្សេងនោះឡើយ។



Scanned with CamScanner

៣-ការសាកសួរសាមីភាគី៖

-ដើមចោទឈ្មោះ [redacted] សំបូរ បានឆ្លើយថា ខ្ញុំបាទបានរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ [redacted] ទីតា ដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ តាមសំបុត្រអាពាហ៍ពិពាហ៍លេខ ២១២/២០០២ ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០០២ ចេញដោយអភិបាលខណ្ឌទួលគោក។ អំឡុងពេលរស់នៅជាប្ដីប្រពន្ធ ខ្ញុំបាទនិងចុងចម្លើយបង្កើតបានកូន ០២នាក់ មានឈ្មោះ [redacted] មុន្នីនាថ ភេទស្រី កើតថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ២០០៣ និងឈ្មោះ [redacted] កន្យាណី កើតថ្ងៃទី ៣០ ខែ តុលា ឆ្នាំ២០០៦។ ក្រោយពេលរៀបអាពាហ៍ពិពាហ៍រួចមក ខ្ញុំបាទនិងចុងចម្លើយរស់នៅមិនចុះសម្រុងរវាងគ្នា ទើបធ្វើឱ្យខ្ញុំបាទអស់មនោសញ្ចេតនារួមរស់ជាមួយគ្នាជាប្ដីប្រពន្ធតទៅទៀត ទើបខ្ញុំបាទសម្រេចចិត្តដាក់ពាក្យបណ្ដឹងមកតុលាការតែម្ដង។

ខ្ញុំបាទសុំលែងលះពីចុងចម្លើយ , សុំប្រគល់សិទ្ធិគ្រប់គ្រងកូនចំនួន ០២នាក់ មានឈ្មោះ [redacted] មុន្នីនាថ ភេទស្រី កើតថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ២០០៣ និងឈ្មោះ [redacted] កន្យាណី កើតថ្ងៃទី ៣០ ខែ តុលា ឆ្នាំ២០០៦ ទៅឱ្យចុងចម្លើយ និងឯកភាពបង់អាហារកាតព្វចិច្ចសម្រាប់ចិញ្ចឹមកូនឈ្មោះ [redacted] កន្យាណី ក្នុងមួយខែ ចំនួន ២០០$ ហើយកូនឈ្មោះ [redacted] មុន្នីនាថ សុំបង់តាមលទ្ធភាពជាក់ស្ដែង។

ចំណែកឯទ្រព្យសម្បត្តិរួមមានផ្ទះចំនួន ០១កន្លែង ស្ថិតនៅផ្ទះលេខ ២D ផ្លូវលេខ ២៧១ ភូមិ១១ ក្រុម៣០ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ខ្ញុំបាទឯកភាពប្រគល់ឱ្យទៅកូនស្រីទាំងពីរ។

-ចុងចម្លើយឈ្មោះ [redacted] ទីតា បានឆ្លើយថា នាងខ្ញុំឯកភាពលែងលះពីដើមចោទ។ ចំពោះកូនចំនួន ០២នាក់ មានឈ្មោះ [redacted] មុន្នីនាថ ភេទស្រី កើតថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ២០០៣ និងឈ្មោះ [redacted] កន្យាណី កើតថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០០៦ នាងខ្ញុំឯកភាពទទួលសិទ្ធិជាអ្នកមានសិទ្ធិអំណាចមេបា និងឱ្យដើមចោទបង់អាហារកាតព្វចិច្ចសម្រាប់ចិញ្ចឹមកូនឈ្មោះ [redacted] កន្យាណី ក្នុងមួយខែ ចំនួន ២០០$ ហើយកូនឈ្មោះ [redacted] មុន្នីនាថ ឱ្យដើមចោទបង់តាមលទ្ធភាពជាក់ស្ដែង។

ចំណែកឯទ្រព្យសម្បត្តិរួមមានផ្ទះចំនួន ០១កន្លែង ស្ថិតនៅផ្ទះលេខ ២D ផ្លូវលេខ ២៧១ ភូមិ១១ ក្រុម៣០ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ នាងខ្ញុំឯកភាពប្រគល់ឱ្យទៅកូនស្រីទាំងពីរ។

## <u>សំអាងហេតុ</u>

ផ្អែកតាមលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាង តុលាការយល់ឃើញថា៖

-ដើមចោទឈ្មោះ [redacted] សំបូរ និងចុងចម្លើយឈ្មោះ អោម ទីតា ពិតជាប្ដីប្រពន្ធស្របច្បាប់ ដែលមានសំបុត្រអាពាហ៍ពិពាហ៍លេខ ២១២/២០០២ ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ២០០២ ចេញដោយអភិបាលខណ្ឌទួលគោក ជាភស្តុតាង។

-តាមកំណត់ហេតុស្ដីពីនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០២៣ ឃើញថា ដើមចោទឈ្មោះ [redacted] សំបូរ និងចុងចម្លើយឈ្មោះ [redacted] ទីតា មានបំណងពិតប្រាកដក្នុងការរំលាយទំនាក់ទំនងចំណងអាពាហ៍ពិពាហ៍ប្រាកដមែន ស្របតាមមាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណី។

-អំឡុងពេលរស់នៅជាមួយគ្នាជាប្ដី-ប្រពន្ធ ដើមចោទឈ្មោះ [redacted] សំបូរ និងចុងចម្លើយឈ្មោះ [redacted] ទីតា បង្កើតបានកូន០២នាក់ មានឈ្មោះ [redacted] មុន្នីនាថ ភេទស្រី កើតថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ២០០៣ ដូចមានក្នុងសំបុត្រកំណើតលេខ ១១៥ ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ២០០៥ និងឈ្មោះ [redacted] កន្យាណី កើតថ្ងៃទី ៣០ ខែ តុលា ឆ្នាំ២០០៦ ដូចមានក្នុងសំបុត្រកំណើតលេខ ១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ២០០៧ ហើយគូភាគីបានឯកភាពគ្នា កំណត់យកចុងចម្លើយឈ្មោះ [redacted] ទីតា ជាអ្នកមានសិទ្ធិអំណាចមេបា និងឱ្យដើមចោទឈ្មោះ [redacted] សំបូរ បង់អាហារកាតព្វកិច្ចសម្រាប់ចិញ្ចឹមកូន ឈ្មោះ [redacted] កន្យាណី ក្នុងមួយខែ ចំនួន ២០០$ ហើយកូនឈ្មោះ [redacted] មុន្នីនាថ បង់តាមលទ្ធភាពជាក់ស្ដែង។ គប្បីតុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគី។

-តាមការអះអាងរបស់ដើមចោទឈ្មោះ [redacted] សំបូរ និងចុងចម្លើយឈ្មោះ [redacted] ទីតា ឃើញថា អំឡុងពេលរស់នៅក្នុងចំណងអាពាហ៍ពិពាហ៍មានទ្រព្យសម្បត្តិរួម ផ្ទះចំនួន ០១កន្លែង ស្ថិតនៅផ្ទះលេខ ២D ផ្លូវលេខ ២៧១ ភូមិ១១



Scanned with CamScanner

ក្រុម៣០ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដូចមានក្នុងវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១២០៤០៦១១-០៣៧៨ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ២០០៩ ហើយបានឯកភាពគ្នាប្រគល់ឱ្យទៅកូនទាំងពីរនាក់ មានឈ្មោះ [redacted] មុន្នីនាថ និងឈ្មោះ [redacted] កន្យាណី។ គប្បីតុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគី។

-ប្រាក់ប្រដាប់ក្តីគប្បីតុលាការសម្រេចតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## សេចក្តីសម្រេចបញ្ចប់

១-ឱ្យដើមចោទឈ្មោះ [redacted] សំបូរ និងចុងចម្លើយឈ្មោះ [redacted] នីតា លែងលះពីគ្នាចាប់ពីថ្ងៃសាលក្រមចូលជាស្ថាពរតទៅ តាមមាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណី។

២-កំណត់យកចុងចម្លើយឈ្មោះ [redacted] នីតា ជាអ្នកមានអំណាចមេបាលើកូន ០២នាក់ ដែលមានឈ្មោះ [redacted] មុន្នីនាថ ភេទស្រី កើតថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ២០០៣ និងឈ្មោះ [redacted] កន្យាណី កើតថ្ងៃទី ៣០ ខែ តុលា ឆ្នាំ២០០៦ តាមការព្រមព្រៀងរបស់គូភាគី។ តាមមាត្រា ១០៣៧ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។

ភាគីដែលពុំមានអំណាចមេបាលើកូន មានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនបាន ហើយភាគីដែលមានអំណាចមេបាលើកូន ត្រូវបង្កលក្ខណៈងាយស្រួលដល់ភាគីដែលពុំមានអំណាចមេបា នៅពេលទៅសួរសុខទុក្ខកូន តាមមាត្រា ១០៤០ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។

៣-ឱ្យដើមចោទឈ្មោះ [redacted] សំបូរ បង់អាហារកាតព្វកិច្ចសម្រាប់ចិញ្ចឹមកូនឈ្មោះ [redacted] កន្យាណី ក្នុងមួយខែចំនួន ២០០$ ហើយកូនឈ្មោះ [redacted] មុន្នីនាថ បង់តាមលទ្ធភាពជាក់ស្តែង តាមការព្រមព្រៀងរបស់គូភាគី។

៤-ទ្រព្យសម្បត្តិរួមមាន ផ្ទះចំនួន ០១កន្លែង ស្ថិតនៅផ្ទះលេខ ២D ផ្លូវលេខ ២៧១ ភូមិ១១ ក្រុម៣០ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដូចមានក្នុងវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១២០៤០៦១១-០៣៧៨ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ២០០៩ ប្រគល់ទៅឱ្យឈ្មោះ [redacted] មុន្នីនាថ និងឈ្មោះ [redacted] កន្យាណី ជាអ្នកមានសិទ្ធិគ្រប់គ្រង។

៥-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

សាលក្រមនេះបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០២៣ ចំពោះមុខដើមចោទ ចុងចម្លើយ និងអ្នកតំណាងដោយអាណត្តិរបស់គូភាគី និង ប្រកាសជាសាធារណៈនៅថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០២៣។

គូភាគីមានសិទ្ធិប្តឹងឧទ្ធរណ៍រយៈពេល ០១(មួយ)ខែ គិតចាប់ពីថ្ងៃទទួលបានសាលក្រមនេះ។

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា [redacted]

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃ ចន្ទ ៩ កើត ខែ មាឃ ឆ្នាំ ខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ , ថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ចៅក្រមជំនុំជម្រះ**

[redacted]